ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពត
លេខៈ..៤៨០..... សជណ/កព

កំពត, ថ្ងៃទី..២៧.. ខែតុលា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចុះបញ្ជីពន្ធដារ

ដោយអនុវត្តតាមប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ និងសារាចរណែនាំលេខ ០០៩ សហវ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកាត់ទុកពន្ធលើប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អភិបាលនៃគណៈអភិបាលខេត្តកំពត មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់ក្រុមហ៊ុន សហគ្រាសទាំងនីតិបុគ្គល និងរូបវន្តបុគ្គល ឬក្រុមអាជីវកម្ម និងនាយកអង្គការនានាទោះស្វែងរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញក្តី និងប្រធានមន្ទីរ-អង្គភាព ស្ថាប័នរដ្ឋនានាជុំវិញខេត្ត ដែលបាននឹងកំពុងធ្វើសកម្មភាពក្នុងទូទាំងខេត្តកំពតទាំងមូល ឱ្យបានជ្រាបអំពីគោលការណ៍ និងវិធានការណ៍នៃការចុះបញ្ជីពន្ធដារដូចខាងក្រោម ÷

**១). កាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារៈ**

-ក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ ម្ចាស់ក្រុមហ៊ុន សហគ្រាសឬក្រុមអាជីវកម្ម ឬបុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ (អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស) ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពេលទទួលបាន ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក្រសួងស្ថាប័នពាក់ព័ន្ធ ។ ករណីមានការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស ការផ្ទេរ ការបញ្ឈប់ ឬមិនសកម្មភាពអាជីវកម្ម ម្ចាស់សហគ្រាស ឬក្រុមអាជីវកម្មត្រូវជូនដំណឹង ឬដាក់ពាក្យស្នើសុំជិះបញ្ជីមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីមានការផ្លាស់ប្តូរ ។

-បណ្តាមន្ទីរ អង្គភាព ស្ថាប័នរដ្ឋជុំវិញខេត្តទាំងអស់ត្រូវចាត់អ្នកតំណាងស្របច្បាប់មកធ្វើការចុះបញ្ជី ដើម្បីងាយស្រួលក្នុងការអនុវត្តន៍ និងដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់បៀវត្សតាមពេលវេលា ដែលច្បាប់ ស្តីពីសារពើពន្ធបានកំណត់ ។

**២). ការស្នើសុំចុះបញ្ជី និងរយៈពេលនៃការចុះបញ្ជីពន្ធដារៈ**

ក). គ្រប់សហគ្រាស និងបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកជន ឬបុគ្គលទាំងឡាយដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារត្រូវធ្វើការស្នើសុំចុះបញ្ជី ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-Registration) ដែលមាននៅក្នុងគេហទំព័រ របស់អគ្គនាយកដ្ឋានពន្ធដារ ។

ខ). ការស្នើសុំចុះបញ្ជីពន្ធដារ ត្រូវបង់ថ្លៃសេវាចុះបញ្ជី ចេញវិញ្ញាបនបត្រចុះបញ្ជី និងប័ណ្ណសម្គាល់ការចុះបញ្ជីក្នុងតម្លៃ ៤០០ ០០០ រៀល (បួនរយពាន់រៀលគត់) សម្រាប់អ្នកជាប់ពន្ធតាមរបបពិត (ស្វ័យប្រកាស) និងចុះបញ្ជីពន្ធដារតាមរបបម៉ៅការត្រូវបង់ថ្លៃសេវា ២០ ០០០ រៀល (ម្ភៃពាន់រៀលគត់) ។/.

គ). ចំពោះសហគ្រាសដែលបានចុះបញ្ជីមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងបណ្ណសម្គាល់ការចុះបញ្ជីថ្មី ដោយតម្រូវឱ្យបង់ថ្លៃសេវាចំនួន ២០០ ០០០ រៀល (ពីររយពាន់រៀលគត់) សម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស និង ១០ ០០០ រៀល (ដប់ពាន់រៀលគត់) សម្រាប់សហគ្រាសជាប់ពន្ធតាមរបបម៉ៅការ ។

ឃ). ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិចត្រូនិក (E-Registration) ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ អាចចំណាយរយៈពេលពី ១ថ្ងៃ ទៅ ៧ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ ។

ង). ចំពោះការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ តាមរយៈការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ អាចនឹងចំណាយរយៈពេលពី ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការក្នុងការចេញវិញ្ញាបនបត្រ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ សម្រាប់ផ្តល់ភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ។

**៣). ការស្នើសុំបញ្ជាក់សាខាសហគ្រាសៈ**

សហគ្រាសដែលបានស្នើសុំចុះបញ្ជីរួចហើយ និងបានបង្កើតសាខារបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំសិខិតបញ្ជាក់សាខាសហគ្រាស ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិចត្រូនិក (E-Registration) ក្នុងគេហទំព័រ របស់អគ្គនាយកដ្ឋានពន្ធដារ ។ ចំពោះរយៈពេលនៃការបញ្ជាក់សាខាគឺដូចមានចែងក្នុងចំណុច (ឃ) និង (ង) នៃចំណុចទី២ខាងលើ ។

**៤). អំពីទោសទណ្ឌៈ**

ការមិនបានចុះបញ្ជីពន្ធដារ ឬមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជីត្រូវទទួលរងទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ។

អភិបាលនៃគណៈអភិបាលខេត្តកំពត មានសេចក្តីសង្ឃឹម ជឿជាក់លើស្មារតីទទួលខុសត្រូវខ្ពស់ របស់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ម្ចាស់សហគ្រាសអាជីវកម្មទាំងអស់ ប្រធានមន្ទីរ-អង្គភាព អង្គការនានាជុំវិញខេត្ត ពិតជាយកចិត្តទុកដាក់អនុវត្តកាតព្វកិច្ច ចុះបញ្ជីពន្ធដារបានត្រឹមត្រូវ និងទាន់ពេលវេលាតាមច្បាប់ជាក់ជាពុំខានឡើយ ។

**អភិបាលខេត្ត**

ខ្លុយ_ឃុនហ៊ួរ

**កន្លែងទទួល:**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
  "ដើម្បីជូនជ្រាប"
- គ្រប់ស្រុក/ក្រុង
- បណ្តាមន្ទីរ-អង្គភាពជុំវិញខេត្ត
  "ដើម្បីសហការអនុវត្ត"
- សាខាពន្ធដារខេត្ត "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ